អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

**សកម្មភាព** ៖ **ល្បែងកាត់និងរាប់ចំនួនតាមសន្លឹកកិច្ចការ**

**ចិត្តចលភាព** ៖ **បំណិនចលករតូច៖** ការហ្វឹកហាត់បង្កើនកម្លាំងនិងសម្របសម្រួលរវាងចលនាសាច់ដុំដៃនិងសាច់ដុំភ្នែក

**ការរីកចម្រើនរាងកាយនិងចលនា៖**

ការរីកចម្រើនកម្លាំងនិងការប្រឈមនិងទប់ទល់ឧបសគ្គពេលធ្វើសកម្មភាពផ្សេងៗ៖

**បុរេគណិត** ៖ **បរិមាណនិងចំនួន៖** ស្គាល់និងយល់លេខតាងនិងការគណនាលេខសាមញ្ញ

ចរិយាសម្បទា៖ មានអំណត់ តស៊ូព្យាយាម និងសប្បាយរីករាយក្នុងពេលដែលធ្វើអ្វីមួយ ឬលេងល្បែងបានរឹងមាំ និងជោគជ័យ។

បំណិនសម្បទា៖ អនុវត្តសកម្មភាពមួយដែលមានភាពទន់ភ្លន់ រហ័សរហួន និងរឹងមាំការចាប់ផ្តើមចេញពីចលនាមូលដ្ឋានងាយៗទៅលំបាក ចំនួនពីរឡើងទៅ ក្នុងនោះមានការដើរ រត់ លោត ឬលើសពីនេះ តាមរយៈ ចលនាចរន្ត ហាត់ប្រាណតាមបទចម្រៀង តាមរឿងនិទាន បទភ្លេងនិងល្បែងនានា។

**គោលបំណង៖**

**ចិត្តចលភាព** ៖ បំណិនសម្បទា៖ កំណត់ចំណុចគោលនៃចលនាដៃដោយការទប់លំនឹង និងសម្របសម្រួលទៅនឹងភ្នែកក្នុងពេលធ្វើអ្វីមួយ ឬលេងល្បែងបានរឹងមាំល្អ។

ចរិយាសម្បទា៖ មានអំណត់ ការតស៊ូព្យាយាម និងសប្បាយចិត្តក្នុងការធ្វើអ្វីមួយ ឬលេងល្បែងបានរឹងមាំល្អ និងជោគជ័យ។

**បុរេគណិត** ៖ វិជ្ជាសម្បទា៖ប្រាប់បានពីចំនួនលេខនិងយល់ន័យពី១ដល់៣០ តាមលំដាប់លំដោយឬលើសពីនេះ។

ចរិយាសម្បទា៖ ឈ្លាសវៃ រហ័សរហួនក្នុងការគិតលេខ។

**កម្រិតសិក្សា** ៖ មធ្យម ខ្ពស់។

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ ដីឥដ្ឋដែលមានពណ៌ កាំបិតជ័រ ក្រដាសសន្លឹកកិច្ចការនិងដីខ្មៅ

**ការរៀបចំ** ៖ ត្រៀមជាមួយក្រដាសនិងសម្ភារទាំងអស់សម្រាប់លេងល្បែងនេះឱ្យគ្រប់។

**សេចក្តីណែនាំ ៖**

1. ប្រាប់កុមារថាថ្ងៃនេះនឹងលេងល្បែងសកម្មភាពមួយនឹងគ្នាគឺល្បែងកាត់និងរាប់ចំនួនតាមសន្លឹកកិច្ចការ។
2. កូនៗស្គាល់ចំនួនដែរឬទេ? កូនៗស្គាល់ពណ៌ដែរឬទេ?
3. បែងចែកកុមារទៅជាក្រុមដែលមានសមាជិត៣នាក់ក្នុងមួយក្រុម(១សម្រាប់កាត់ដីឥដ្ឋ១ពណ៌សម្រាប់មួយក្រុម។
4. វិធីលេង៖ ចែកសម្ភារសម្រាប់លេងទៅតាមក្រុមនីមួយៗឱ្យបានគ្រប់
    - កុមារទី១ក្នុងក្រុមត្រូវកាន់ដីឥដ្ឋដែលមាន៣ឬ៤ពណ៌និងត្រៀមសម្រាប់កាត់ទៅតាមចំនួនដែលកុមារម្នាក់ទៀតប្រាប់ ដោយប្រើកាំបិតជ័រឬអ្វីក៏បានដែលអាចកាត់បាន
    - កុមារម្នាក់ទៀតត្រូវរាប់ចំនួនដែលកុមារទី១បានកាត់ជាចំនួននោះ
    - ចុងក្រោយកុមារម្នាក់ទៀតត្រូវចាំសរសេរចំនួនដែលកុមារទី២បានរាប់នៅលើចានស្មោនោះជាការស្រេច។
    - ពេលតាមក្រុមនីមួយៗកាត់រួច សរសេរចំនួនរួច គ្រូត្រូវតែត្រួតពិនិត្យផងថាកុមារតាមក្រុមនីមួយៗបានធ្វើត្រឹមត្រូវដែរឬទេ។
5. នៅពេលលេងចប់ឱ្យកុមារជួយរៀបចំទុកដាក់សម្ភារលេខឱ្យមានរបៀបរៀបរយជាការស្រេច។

**ការប្រែប្រួលៈ**

ល្បែងនេះអាចលេងបានច្រើនបែបច្រើនសណ្ឋានដែរ ដូចជា អ្នកអាចលេងបែបជា ក្រុមដដែល តែអ្នកអាចសសេរចំនួនលេខនៅលើចានស្មោនោះ បន្ទាប់មក

ឱ្យកុមារតាមក្រុមនីមួយកាត់ពណ៌ជាចំនួនឱ្យត្រូវនឹងចំនួននៅលើចានស្មោជាការស្រេច។

ល្បែងយើងចង់ឱ្យកុមារបានចឹងនិងស្គាល់ចំនួនផងដែរ។